# ឧបសម្ព័ន្ធ ១

## ការពិចារណាលើតាក្យដើមបណ្តឹងរដ្ឋប្បវេណី ឧបសម្ព័ន្ធ ឃ (ភូមិភាគកណ្តាល)

| លេខយោងVSS | ឈ្មោះពេញរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី | សំអាងហេតុរបស់អង្គបុរេជំនុំជម្រះពាក់ព័ន្ធនឹងកំហុសឆ្គងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ | ការពិចារណាលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី |
|---|---|---|---|
| 16-VSS-00070 | បៃ សុផានី | អ្នកដាក់ពាក្យបានរៀបរាប់អំពីការស្លាប់របស់កុមារក្រៅភូមិភាគកណ្តាលនិងការស្លាប់របស់សមាជិកគ្រួសារ ជាច្រើនទៀតនៅក្នុងពេលវេលានិងទីកន្លែងផ្សេងៗគ្នា ដែលមិនបានកំណត់ជាក់លាក់។ ដូចដែលបញ្ជាក់ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ អង្គហេតុទាំងនេះស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង។ | ពាក្យសុំនេះ**មិនអាចទទួលយកបាន**។ សេចក្តីសម្រេចរបស់សហចៅក្រស៊ើបអង្កេតអន្តរជាតិត្រូវបាន**បញ្ជាក់**។ |
| 13-VSS-00316 | ដន ណាត | សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានប្រព្រឹត្តកំហុសឆ្គងមួយ។ អង្គហេតុមួយចំនួនដែលត្រូវបានរៀបរាប់ គឺស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង រួមទាំងការបង្ខំឲ្យអ្នកដាក់ពាក្យរៀបការនៅក្នុងខេត្តកំពង់ចាមក្នុងឆ្នាំ១៩៧៥ ប៉ុន្តែអ្នកដាក់ពាក្យបានរៀបរាប់អំពីអំពើទាសភាព និង អំពើអមនុស្សធម៌ដទៃទៀតនៅក្នុងស្រុកចំការ | សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានប្រព្រឹត្តកំហុស។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (D5/1336) គួរតែត្រូវបាន**ទទួលយក**។ |

| | | | |
|---|---|---|---|
| | | លើ ខេត្តកំពង់ចាម ពីឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៨។ ហេតុការណ៍ទាំងនេះស្ថិតក្នុងវិសាលភាពនៃសំណុំរឿង។ | |
| 12-VSS-00518 | ហូ គន្ធា | អ្នកដាក់ពាក្យបានរៀបរាប់អំពីអំពើទាសភាពដោយបង្ខំ និង អំពើអមនុស្សធម៌ដទៃទៀតដែលប្រព្រឹត្តលើគាត់នៅចុងឆ្នាំ១៩៧៦ និង ការសម្លាប់ម្តាយរបស់គាត់នៅក្នុងមន្ទីរសន្តិសុខវត្តជ្រោយអំពិលក្នុងភូមិជ្រោយអំពិល ឃុំចំបក់ ស្រុកព្រៃកប្រសប់ ខេត្តក្រចេះ ឆ្នាំ១៩៧៧។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសឆ្គងដែល បានបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះ។ ស្រុកព្រៃកប្រសប់ស្ថិតនៅក្នុងតំបន់៤២ ក្នុងភូមិភាគកណ្តាល ហើយហេតុការណ៍ទាំងនេះស្ថិតក្នុងវិសាលភាពពេលវេលានៃសំណុំរឿង។ | សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសឆ្គង។ពាក្យសុំតាំងខ្លួនជាដើម បណ្តឹងរដ្ឋប្បវេណី (D5/376) គួរតែត្រូវបាន **ទទួលយក**។ |
| 13-VSS-00103 | កែវ រ័ត្នធារ៉ា | អ្នកដាក់ពាក្យសុំបានរៀបរាប់អំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្រៅវិសាលភាពដែនដីនៃសំណុំរឿង រួមទាំងអំពើទាសភាពនៅក្នុងខេត្តបាត់ដំបង ផងដែរ។ អ្នកដាក់ពាក្យក៏បានរៀបរាប់អំពីមនុស្សឃាតលើបងប្អូនប្រុសនិងជីដូនមួយរបស់គាត់នៅវត្តបារ៉ាយជាន់ដែក ស្រុកបារាយ ខេត្តកំពង់ធំក្នុងឆ្នាំ១៩៧៦។ ប៉ុន្តែ អ្នកដាក់ពាក្យពុំបានផ្តល់ការបញ្ជាក់ច្បាស់លាស់បន្ថែមទៀតអំពីពេលវេលានៃការសម្លាប់ នៅក្នុងឆ្នាំ១៩៧៦ឡើយ។ ការ | ពាក្យសុំ **មិនអាចទទួលយកបាន**។ សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិត្រូវបាន**បញ្ជាក់**។ |

| | | | |
|---|---|---|---|
| | | កំណត់របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិថា អង្គហេតុដែលបានរៀបរាប់ស្ថិតក្រៅវិសាលភាពនៃសំណុំរឿង គឺមិនមែនមិនសមហេតុផលនោះទេ។ | |
| 16-VSS-00052 | ខៀវ តុល | អ្នកដាក់ពាក្យបានរៀបរាប់អំពីឧក្រិដ្ឋកម្មនៅក្នុងឆ្នាំ ១៩៧៥ និង១៩៧៦ ក្នុងស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ប៉ុន្តែមិន បានបញ្ជាក់ច្បាស់លាស់អំពីក្របខ័ណ្ឌពេលវេលាបន្ថែម ឡើយ។ ដូចដែលបង្ហាញដោយសហចៅក្រមស៊ើបអង្កេត អន្តរជាតិ កាលបរិច្ឆេទនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ ក៏មានលក្ខណៈមិនច្បាស់លាស់ពេកក្នុងការកំណត់ថាតើ ឧក្រិដ្ឋកម្មទាំងនោះបានកើតឡើងនៅក្នុងវិសាលភាពពេលវេលានៃសំណុំរឿងឬទេ។ | ពាក្យសុំ **មិនអាចទទួលយកបាន**។ សេចក្ដីសម្រេចរបស់សហចៅក្រមសើបអង្កេតអន្តរជាតិត្រូវបាន**បញ្ជាក់**។ |
| 11-VSS-00024 | ឃី ណាត | ដូចដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិពន្យល់ហេតុ ការណ៍ដែលបានរៀបរាប់ ក្នុងនោះរួមទាំងការរៀបការ ដោយបង្ខំរបស់បងប្អូនស្រីរបស់អ្នកដាក់ពាក្យក្នុងឆ្នាំ១៩៧៥ ក្នុងស្រុកកំពង់សៀម គឺស្ថិតនៅក្រៅវិសាលភាពពេលវេលា នៃសំណុំរឿង។ | ពាក្យសុំ **មិនអាចទទួលយកបាន**។ សេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិត្រូវបាន**បញ្ជាក់**។ |
| 11-VSS-00024 | ឃី ណាត | ដូចដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិពន្យល់ហេតុ ការណ៍ដែលបានរៀបរាប់ ក្នុងនោះរួមទាំងការ | ពាក្យសុំ **មិនអាចទទួលយកបាន**។ សេចក្ដីសម្រេចរបស់ |

| | | | |
|---|---|---|---|
| | | រៀបការ ដោយបង្ខំរបស់បងប្អូនស្រីរបស់អ្នកដាក់ពាក្យក្នុងឆ្នាំ១៩៧៥ ក្នុងស្រុកកំពង់សៀម គឺស្ថិតនៅក្រៅវិសាលភាពពេលវេលា នៃសំណុំរឿង។ | សហចៅក្រមស៊ើបអង្កេតអន្តរជាតិត្រូវបាន**បញ្ជាក់**។ |
| 13-VSS-00631 | ម៉ៅ សើឡេស | វាពុំមែនមិនសមហេតុផលសម្រាប់សហចៅក្រមស៊ើបអង្កេតអន្តរជាតិក្នុងការចាត់ទុកពាក្យសុំមិនអាចទទួលយកបាននោះទេ ប៉ុន្តែសំអាងហេតុរបស់គាត់បែបនេះគឺមិនត្រឹមត្រូវ។<br><br>សហចៅក្រមស៊ើបអង្កេតអន្តរជាតិថ្លែងដោយត្រឹមត្រូវថា អង្គហេតុទាំងនេះស្ថិតក្រៅវិសាលភាពដែនដី ប៉ុន្តែគាត់មានកំហុសឆ្គងក្នុងការបញ្ចេញមតិថាអ្នកដាក់ពាក្យស្ថិតក្រៅវិសាលភាពពេលវេលាផងដែរ(ពីព្រោះអ្នកដាក់ពាក្យបាន រៀបរាប់ហេតុការណ៍ ក្នុងនោះរួមមានរង្វង់ឆ្នាំ១៩៧៦ដល់ ១៩៧៨)។ ពុំមែនមិនសមហេតុផលទេសម្រាប់សហចៅក្រមស៊ើបអង្កេតអន្តរជាតិចាត់ទុកអ្នកដាក់ពាក្យមិនអាចទទួលយក បានដោយហេតុថាព្យសនកម្មតាមការចោទប្រកាន់របស់អ្នកដាក់ពាក្យពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលស្ថិតក្រៅវិសាលភាពដែនដីនៃសំណុំរឿង (ក្នុងស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម) ក្រៅភូមិភាគកណ្តាល។ ភូមិសាស្ត្រនេះត្រូវបានទទួលស្គាល់បន្ថែមដោយអំ | ពាក្យសុំ **មិនអាចទទួលយកបាន**។ សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិត្រូវបាន**បញ្ជាក់**។ |

| | | | |
|---|---|---|---|
| | | ណះអំណាងរបស់មេធាវីតំណាង ដើមបណ្ដឹងរដ្ឋប្បវេណីដែលថាអ្នកដាក់ពាក្យត្រូវបានរងព្យសនកម្មនៅក្នុងភូមិភាគនីរតី។ | |
| 16-VSS-00059 | មាស យ៉ុន | អ្នកដាក់ពាក្យបានរៀបរាប់អំពីព្យសនកម្មដែលពាក់ព័ន្ធនឹង ហេតុការណ៍ដែលបានកើតឡើងក្នុងឆ្នាំ១៩៧៥និងពាក់ កណ្ដាល ឆ្នាំ១៩៧៦។ ដូចដែលបានបង្ហាញដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ហេតុការណ៍ទាំងនេះស្ថិតនៅក្រៅវិសាលភាពពេលវេលានៃសំណុំរឿង។ | ពាក្យសុំ **មិនអាចទទួលយកបាន**។ សេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិត្រូវបាន**បញ្ជាក់**។ |
| 13-VSS-00395 | នាង សាខន | ដូចដែលបានបង្ហាញដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ អង្គហេតុដែលត្រូវបានរៀបរាប់ ក្នុងនោះរួមទាំងការជម្លៀសដោយបង្ខំលើអ្នកដាក់ពាក្យ ពីភ្នំពេញ និង ការស្លាប់របស់សមាជិកគ្រួសារក្នុងខេត្តព្រៃវែង គឺស្ថិតក្រៅវិសាលភាពនៃសំណុំរឿង។ | ពាក្យសុំ **មិនអាចទទួលយកបាន**។ សេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិត្រូវបាន**បញ្ជាក់**។ |
| 11-VSS-00059 | ញ៉ែម ខាន់ | អ្នកដាក់ពាក្យបានរៀបរាប់ហេតុការណ៍ដែលបានកើតឡើង ក្នុងខេត្តកំពង់ធំក្នុងឆ្នាំ១៩៧៦ និងមិនបញ្ជាក់កាលបរិច្ឆេទឲ្យបានច្បាស់។ ក្របខ័ណ្ឌពេលវេលានៃហេតុការណ៍ទាំងនេះមិនមានលក្ខណៈជាក់លាក់គ្រប់គ្រាន់ និង | សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសឆ្គង។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី(D5/211) គួរតែត្រូវបាន**ទទួលយក**។ |

| | | | |
|---|---|---|---|
| | | មិនច្បាស់ថាតើហេតុការណ៍ ទាំងនោះស្ថិតនៅក្នុងវិសាលភាពពេលវេលានៃសំណុំរឿងឬទេ។ ប៉ុន្តែនៅក្នុងព័ត៌មានបន្ថែម អ្នកដាក់ពាក្យបានរៀបរាប់ថាគាត់ ត្រូវបានបង្ខំឲ្យធ្វើការនៅតាមការដ្ឋាននានា រួមទាំងនៅការដ្ឋានកំពង់ថ្ម ក្នុងខេត្តកំពង់ធំនៅចុងឆ្នាំ១៩៧៦។ ហេតុការណ៍ដែល បានរៀបរាប់នេះស្ថិតនៅក្នុងវិសាលភាពពេលវេលានិងដែនដីនៃសំណុំរឿង។ សហចៅក្រមស៊ើបអង្កេតមានកំហុសឆ្គង ដែលបដិសេធពាក្យសុំនេះ។ | |
| 12-VSS-00672 | ញឹម កុល | សេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិក្នុង ការប្រកាសថាពាក្យសុំរបស់ ញឹម កុល ថាមិនអាចទទួលយកបានដោយហេតុថាគាត់ជាកម្មាភិបាលខ្មែរក្រហមគឺជាកំហុសឆ្គង។ កាលពីមុន ក្នុងសំណុំរឿង ០០២ កម្មាភិបាលខ្មែរក្រហមជាច្រើន នាក់ត្រូវបានទទួលស្គាល់ជាដើមបណ្ដឹងរដ្ឋប្បវេណី រួមទាំង ដើមបណ្ដឹងរដ្ឋប្បវេណី ឈុន សាម៉ន (D22/2479) និងដើមបណ្ដឹងរដ្ឋ ប្បវេណី 2-TCCP-235, ដែលអ្នកទាំងពីរ គឺសុទ្ធតែជាទាហានខ្មែរក្រហម។<br><br>ចំពោះឧក្រិដ្ឋកម្មនៅក្នុងវិសាលភាពពេលវេលានិងដែនដីនៃ សំណុំរឿង ញឹម កុល រៀបរាប់ការចាប់ខ្លួនមួយចំនួន | សហចៅក្រមស៊ើបអង្កេតមានកំហុសឆ្គង។ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី(D5/676)គួរតែត្រូវបាន **ទទួលយក**។ |

| | | | |
|---|---|---|---|
| | | និង មនុស្សឃាតលើសាច់ញាតិគ្រួសារគាត់ រួមទាំង មនុស្សឃាត លើពូរបស់គាត់ឈ្មោះ ញឹម ជ័យ ជាអតីតទាហាន លន់ នល់ និងគ្រួសារគាត់នៅភ្នំប្រុសភ្នំស្រីក្នុងឆ្នាំ១៩៧៧ (*ប្រៀបធៀបនឹងសំណុំរឿង* D5/676 ត្រង់ ERN 01541039។ អំពើទារុណកម្ម និងមនុស្សឃាតបន្ទាប់មក លើពូរបស់គាត់ឈ្មោះ (ឈួន ស៊ឹម ឆ្នាំ១៩៧៧ ឬ១៩៧៨ (*ប្រៀបធៀបនឹងសំណុំរឿង* D219/171 ឆ.២៥)។ និងការចាប់ពូរបស់កាត់ឈ្មោះ (ផាន ស៊ឹម អតីតប្រធានឃុំ និងសមាជិកគណៈ) នៅមន្ទីរ សន្តិសុខតំបន់នៅវត្តតាមាក់ជាផ្នែកមួយនៃការបោសសម្អាត កម្មាភិបាលក្នុងតំណែង ក្រោយពេលក្រុមនិរតីមកដល់ ភូមិភាគកណ្ដាល (*ប្រៀបធៀបនឹងសំណុំរឿង* D219/171, ឆ១១, ឆ១៦)។<br><br>ពីខែមិថុនា ឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៩ ញឹម កុល ទទួលខុស ត្រូវអង្គភាពពាណិជ្ជកម្មនៃឃុំក្រឡា និងទទួលខុសត្រូវបែងចែក អង្ករនិងអំបិលនៅថ្នាក់ឃុំ ធ្វើកំណត់ហេតុកិច្ចប្រជុំថ្នាក់ឃុំ ថ្នាក់ ស្រុក ទុកដាក់ឯកសារនិងស្ថិតិប្រជាជននិងការបង្កបង្កើនផល និងការជ្រើសរើសមនុស្សឲ្យធ្វើការនៅចំការនានានៅស្រុកចំការលើ តំបន់ | |

| | | | |
|---|---|---|---|
| | | ៤២។ ការណ៍ដែលថាអ្នកដាក់ពាក្យបានឃើញទារុណកម្មចំពោះពូរបស់គាត់ម្នាក់ (ឈ្មួន ស៊ីម) ខណៈដែលគាត់ជា កម្មាភិបាលខ្មែរក្រហម មិនបដិសេធគាត់ពីឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីទេ។ ទោះបីជា ញ៉ឹម កុល កំពុង "ឈរនៅទីនោះ" នៅខណៈពូរបស់គាត់ កំពុងត្រូវបានសួរចម្លើយក្តី ក៏ប៉ុន្តែមេបញ្ជាការយោធាខ្មែរក្រហមម្នាក់ (ផុន) កំពុងធ្វើការសួរចម្លើយ ហើយពុំមានការបង្ហាញថា ញ៉ឹម កុល បានចូលរួមក្នុងឬបានប្រព្រឹត្តទារុណកម្មឡើយ។ ជាការពិត ភស្តុតាងបញ្ជាក់ថា ញ៉ឹម កុល ពុំមានអំណាចក្នុងការបញ្ឈប់ ទារុណកម្មឡើយ (*ប្រៀបធៀបនឹងសំណុំរឿង* D219/171 ឆ.២៦៖ "ខ្ញុំមានអារម្មណ៍ឈឺចាប់ នៅពេលខ្ញុំនឹកឃើញពាក្យរបស់គាត់ប្រាប់ខ្ញុំឲ្យមើលកូនគាត់ផង"។ សៈ "តើការសួរចម្លើយនោះជាគំនិតរបស់ ផុន ឬ ប្រាក់ យុត?" ឆ២៩៖ "ខ្ញុំគិតថាពួកគេធ្វើខ្លួនឯង")។ តាមពិត ញ៉ឹម កុល ត្រូវបាន ប្រាប់ក្រោយមកថា ពូរបស់គាត់ត្រូវបាន "យកទៅសម្លាប់" ដែលជាការបង្ហាញថាគាត់មិនមានវត្តមាននៅពេលសម្លាប់ទេ។ | |

| | | | |
|---|---|---|---|
| | | ជាពិសេស នៅក្នុងករណីណាក៏ដោយ គឺពុំមានភស្តុតាងបង្ហាញថា ញឹម កុល គឺជាអ្នកប្រព្រឹត្តឬចូលរួមក្នុងការចាប់ខ្លួន និងការស្លាប់របស់សាច់ញាតិគ្រួសាររបស់គាត់ឡើយ រួមទាំងពូរបស់គាត់ពីរនាក់ផ្សេងទៀត(រៀបរាប់ខាងលើ) ហើយសហចៅក្រម ស៊ើបអង្កេតអន្តរជាតិក៏ពុំរកឃើញបែបបែបនេះនៅក្នុងសម្អាងហេតុរបស់ខ្លួនដែរ។ | |
| 13-VSS-00697 | ប៉េង ញ៉ូន | ដូចដែលបានបង្ហាញដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ហេតុការណ៍ស្ទើរតែទាំងអស់ដែលបានរៀបរាប់ស្ថិតនៅក្រៅវិសាលភាពពេលវេលានៃសំណុំរឿង ឬពេលវេលានៃ ហេតុការណ៍ មិនជាក់លាក់គ្រប់គ្រាន់ក្នុងការកំណត់ថាតើ ហេតុការណ៍នោះបានកើតឡើងនៅក្នុងវិសាលភាពនៃសំណុំរឿង ឬទេ។ ប៉ុន្តែ អ្នកដាក់ពាក្យសុំ ក៏បានរៀបរាប់អំពីអំពើទាសភាព និង អំពើអមនុស្សធម៌ដទៃទៀតចាប់ពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩នៅក្នុងទី តាំងនានាដែរ។ គាត់រៀបរាប់ថាគាត់ត្រូវបានបញ្ជូនទៅកាត់វល្លិ៍ ក្នុងខេត្តព្រះវិហារក្នុងឆ្នាំ១៩៧៦ និង ត្រូវបានបង្ខំឲ្យធ្វើការដោយ គ្មានសម្រាក។ ក្រោយមក គាត់ត្រូវបានបញ្ជូនទៅផ្សារកំពង់ចាម លី | សហចៅក្រមស៊ើបអង្កេតអន្តរជាតិមាន កំហុសឆ្គង។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (D5/1429)គួរតែ ត្រូវបាន **ទទួលយក**។ |

| | | | |
|---|---|---|---|
| | | សែងស៊ីម៉ង់ត៍ និងអំបិល និងត្រូវបានបញ្ជាឲ្យលើសែង រំសេវ នៅពេលយប់។ ដោយពិចារណាថាផ្សារកំពង់ចាមគឺជាទីតាំងចុងក្រោយដែលត្រូវបានរៀបរាប់ដោយអ្នកដាក់ពាក្យ និងថា ការធ្វើពលកម្មដោយបង្ខំ បន្តរហូតដល់ឆ្នាំ១៩៧៩ ហេតុការណ៍ទាំងនេះហាក់ដូចជាស្ថិត ក្នុងវិសាលភាពពេលវេលា និងដែនដី នៃសំណុំរឿង។ ដូច្នេះ សហចៅក្រមស៊ើបអង្កេតមានកំហុសក្នុងការបដិសេធពាក្យសុំ។ | |
| 16-VSS-00020 | ផន សុផាត | យោងតាមការរៀបរាប់របស់គាត់ អ្នកដាក់ពាក្យនិងគ្រួសាររបស់គាត់ទទួលរងព្យសនកម្មពីឧក្រិដ្ឋកម្មនានាដែលប្រព្រឹត្តលើគាត់និងគ្រួសាររបស់គាត់ក្នុងឆ្នាំ១៩៧៦ នៅស្រុកព្រៃឈរ និងស្រុកកំពង់សៀម ក្នុងខេត្តកំពង់ចាម ភូមិភាគកណ្តាល។ ទោះបីជា មិនច្បាស់ថាឧក្រិដ្ឋកម្មភាគច្រើនត្រូវបានប្រព្រឹត្តក្នុងចុងឆ្នាំ ១៩៧៦ ឬហួសពីឆ្នាំនោះ ប៉ុន្តែពុំមានហេតុផលឡើយដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិសន្និដ្ឋានថាការបង្ខំឲ្យធ្វើការ និងអំពើអមនុស្សធម៌ដទៃទៀតដែលត្រូវបានរៀបរាប់ទំនងជា ស្ថិតក្រៅវិសាលភាពពេលវេលានៃសំណុំរឿង ដោយពិចារណាដល់លក្ខណៈបន្តរហូតនៃការធ្វើការដោយបង្ខំ និងអំពើអមនុស្សធម៌ដទៃទៀតនៅក្នុងរយៈ | សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសឆ្គង។ ពាក្យសុំតាំងខ្លួនជា ដើមបណ្តឹងរដ្ឋប្បវេណី (D5/1863) គួរតែត្រូវបាន **ទទួលយក**។ |

| | | | |
|---|---|---|---|
| | | ពេលនៃរបបខ្មែរក្រហម ដូចដែលអ្នកដាក់ពាក្យបានរៀបរាប់។ | |
| 15-VSS-00113 | ប៉ោ ឌឿ | ដូចដែលបានបង្ហាញដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ អ្នកដាក់ពាក្យបានរៀបរាប់ហេតុការណ៍ដែលស្ថិតក្រៅវិសាល ភាពដែនដីនិង/ឬពេលវេលានៃសំណុំរឿង រួមទាំងអំពើទាសភាពក្នុង ស្រុកកំពង់សៀម ក្នុងឆ្នាំ១៩៧៥ និងមនុស្សឃាតសាច់ញាតិ របស់គាត់នៅក្នុងខេត្តតាកែវ។ | ពាក្យសុំមិនអាច**ទទួលយកបាន**។ សេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិត្រូវបាន**បញ្ជាក់**។ |
| 11-VSS-00068 | ពួក ជាម | អ្នកដាក់ពាក្យបានរៀបរាប់ការសម្លាប់បងប្អូនបង្កើតរបស់គាត់ ក្នុងស្រុកកំពង់ស្វាយ ខេត្តកំពង់ធំក្នុងឆ្នាំ១៩៧៦ និង ការធ្វើការដោយបង្ខំ/ការបង្អត់អាហារ។ ក្របខ័ណ្ឌពេលវេលាមិនត្រូវបានបញ្ជាក់ច្បាស់លាស់បន្ថែម ហើយគេមិនអាចសន្និដ្ឋានថាហេតុការណ៍ទាំងនេះបានកើតឡើងនៅក្នុងវិសាលភាពពេលវេលានៃសំណុំរឿងនេះឡើយ។ ហេតុដូច្នេះ ពុំមានហេតុផលដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិសន្និដ្ឋានថាហេតុការណ៍ទាំងនេះ ស្ថិតនៅក្រៅវិសាលភាពនាំសំណុំរឿងឡើយ។ | ពាក្យសុំមិនអាច**ទទួលយកបាន**។ សេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិត្រូវបាន**បញ្ជាក់**។ |
| 11-VSS-00346 | ពុត អេង | អ្នកដាក់ពាក្យសុំបានរៀបរាប់អំពីការសម្លាប់សមាជិកគ្រួសាររបស់គាត់នៅក្នុងរង្វង់ឆ្នាំ១៩៧៦ នៅស្រុកកំពង់សៀម ខេត្តកំពង់ចាម។ អ្នកដាក់ពាក្យមិនបានផ្ដល់សេច | ពាក្យសុំមិនអាច**ទទួលយកបាន**។ សេចក្ដីសម្រេចរបស់ |

| | | | |
|---|---|---|---|
| | | ក្ដីលម្អិតគ្រប់គ្រាន់ក្នុងការកំណត់ថា តើហេតុការណ៍នោះបានកើតឡើងនៅក្នុងវិសាលភាពពេលវេលា នៃសំណុំរឿងឡើយ។ មិនតែប៉ុណ្ណោះ ការរៀបរាប់ដំណើររឿងគឺ ពុំមានសង្គតិភាព។ អ្នកដាក់ពាក្យ ដំបូងចោទថា ឧក្រិដ្ឋកម្ម បានកើតឡើងប្រហែលក្នុងឆ្នាំ១៩៧៧ ហើយក្រោយមកបង្ហាញ ថាហេតុការណ៍ទាំងនេះលេចឮក្នុងរង្វង់ឆ្នាំ១៩៧៦។ ហេតុដូច នេះ ពុំមានហេតុផលដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ សន្និដ្ឋានថាហេតុការណ៍ទាំងនេះបានកើតឡើងក្រៅវិសាលភាព ពេលវេលានៃសំណុំរឿងឡើយ។ | សហចៅក្រមស៊ើបអង្កេតអន្តរជាតិត្រូវបាន**បញ្ជាក់**។ |
| 15-VSS-00116 | សាង វន្នី | អ្នកដាក់ពាក្យបានរៀបរាប់ពីអំពើទាសភាព ការធ្វើពលកម្មដោយបង្ខំ ការសម្លាប់ និងការបង្អត់អាហារលើសមាជិកគ្រួសាររបស់គាត់ នៅកោះកុង។ ចំណុចនេះគឺស្ថិតក្រៅវិសាលភាពដែនដីនៃសំណុំ រឿង។ អ្នកដាក់ពាក្យបានរៀបរាប់អពីការសម្លាប់ពូនិងសមាជិកគ្រួសាររបស់គាត់នៅស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ប៉ុន្តែគាត់មិនបាន  បញ្ជាក់នូវកាលបរិច្ឆេទ ឬក្របខ័ណ្ឌពេលវេលាឡើយ។ ហេតុដូចនេះ សេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងការបដិសេធពាក្យសុំនេះ គឺពុំមែនមិនសមហេតុផលនោះទេ។ | ពាក្យសុំមិនអាច**ទទួលយកបាន**។ សេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិត្រូវបាន**បញ្ជាក់**។ |

| | | | |
|---|---|---|---|
| 13-VSS-00394 | សៅ និមិត្ត | អ្នកដាក់ពាក្យសុំបានរៀបរាប់ហេតុការណ៍នានាដែលក្នុង នោះ រួម មានការសម្លាប់សមាជិកគ្រួសារនៅក្នុងស្រុក ស្ទឹងត្រង់ ខេត្តកំពង់ ចាម ស្រុកសំបូរ ក្រចេះ និង ស្រុក ស្នួល ខេត្តក្រចេះ អមជាមួយការរៀបរាប់លម្អិតអំពី ហេតុការណ៍ផ្សេងទៀតក្នុងខេត្តមណ្ឌលគិរី។ ការសម្លាប់ នៅស្រុកស្ទឹងត្រង់ (ខណៈដែលកំពុងកើតឡើងនៅ ក្នុង ភូមិភាគកណ្ដាល)លេចឮនៅក្នុងឆ្នាំ១៩៧៥ និង ស្ថិត ក្រៅ វិសាលភាពពេលវេលានៃសំណុំរឿង។ ទីតាំងផ្សេ ទៀតគឺស្ថិតក្រៅភូមិភាគកណ្ដាល ហើយដូចដែលបាន បង្ហាញដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ គឺស្ថិត នៅក្រៅវិសាលភាពនៃសំណុំរឿង។ | ពាក្យសុំមិនអាច**ទទួលយក បាន**។ សេចក្ដីសម្រេចរបស់ សហចៅក្រមស៊ើបអង្កេត អន្តរជាតិត្រូវបាន**បញ្ជាក់**។ |
| 13-VSS-000397 | សោម អឿន | អ្នកដាក់ពាក្យបានរៀបរាប់អំពីហេតុការណ៍នានាក្នុងនោះ រួមមាន ការស្លាប់របស់សមាជិកគ្រួសារ ក្នុងស្រុកឆ្លូង ខេត្តក្រចេះ។ ស្រុកនេះមិនស្ថិតនៅក្នុងភូមិភាគកណ្ដា លទេ ហើយដូចដែល សហចៅក្រមស៊ើបអង្កេតអន្តរ ជាតិបានបង្ហាញគឺស្ថិតក្រៅវិសាលភាពដែនដីនៃសំណុំរឿ ង។ | ពាក្យសុំមិនអាច**ទទួលយក បាន**។ សេចក្ដីសម្រេចរបស់ សហចៅក្រមស៊ើបអង្កេត អន្តរជាតិត្រូវបាន**បញ្ជាក់**។ |
| 15-VSS-00152 | ស លាត | អ្នកដាក់ពាក្យសុំបានរៀបរាប់ការរៀបអាពាហ៍ពិពាហ៍ ដោយបង្ខំ អំពើទាសភាព អំពើអមនុស្សធម៌ផ្សេទៀត និងការសម្លាប់បងប្អូនបង្កើតរបស់គាត់ និង សមាជិក | ពាក្យសុំមិនអាច**ទទួលយក បាន**។ សេចក្ដីសម្រេចរបស់ |

| | | | |
|---|---|---|---|
| | | គ្រួសារដទៃទៀតក្នុងខេត្តកំពង់ចាមនៅចុងឆ្នាំ១៩៧៨។ ហេតុការណ៍ភាគច្រើនហាក់ដូចជាបាន កើតឡើងនៅស្រុកត្បូងឃ្មុំ ដែលស្ថិតនៅក្រៅភូមិភាគកណ្តាល។ អ្នកដាក់ពាក្យសុំថ្លែងថាបងប្អូនបង្កើតរបស់គាត់មួយចំនួនត្រូវ បានសម្លាប់នៅទីតាំងដទៃទៀតក្នុងខេត្តកំពង់ចាម។ ប៉ុន្តែគាត់ ពុំបានផ្តល់ព័ត៌មានបន្ថែមដែលអាចបញ្ជាក់បំភ្លឺថាតើហេតុការណ៍ទាំងនេះបានកើតឡើងនៅក្នុងវិសាលភាពដែនដីនៃសំណុំរឿងឡើយ។ ការកំណត់របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិថាអង្គហេតុ ស្ថិតក្រៅវិសាលភាពសំណុំរឿងគឺមិនមែនមិនសមហេតុផលនោះទេ។ | សហចៅក្រមស៊ើបអង្កេតអន្តរជាតិត្រូវបាន**បញ្ជាក់**។ |
| 15-VSS-00118 | សូវ សារី | សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនមានកំហុសឆ្គងឡើយ។ ដូចដែលបានបង្ហាញ ហេតុការណ៍ដែលបានរៀបរាប់គឺស្ថិតនៅ ក្រៅវិសាលភាពនៃសំណុំរឿង។ មិនតែប៉ុណ្ណោះ មានអសង្គតិភាព ជាក់ស្តែងនៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹង រដ្ឋប្បវេណី និង ព័ត៌មានបន្ថែមដែលបានផ្តល់។ | ពាក្យសុំមិនអាច**ទទួលយកបាន**។ សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិត្រូវបាន**បញ្ជាក់**។ |
| 11-VSS-00140 | ស៊ាង យ៉យ | អ្នកដាក់ពាក្យបានរៀបរាប់ការសម្លាប់បងប្រុសរបស់គាត់ នៅភ្នំ ប្រុសក្នុងស្រុកកំពង់សៀម ខេត្តកំពង់ចាមក្នុងចំណោមបញ្ហា ដទៃទៀត។ អ្នកដាក់ ពាក្យដំបូង | ពាក្យសុំមិនអាច**ទទួលយកបាន**។ សេចក្តីសម្រេចរបស់ |

| | | | |
|---|---|---|---|
| | | បង្ហាញថាឧក្រិដ្ឋកម្មបានកើត ឡើងនៅក្នុងឆ្នាំ១៩៧៧។ ប៉ុន្តែនៅពេលរៀបរាប់លម្អិតអំពីហេតុ ការណ៍ អ្នកដាក់ពាក្យបានរៀបរាប់ថា “បងប្រុសខ្ញុំ ស៊ាង ឆែម [...] ត្រូវបានគេយកទៅសម្លាប់នៅភ្នំប្រុសភ្នំស្រី ប្រហែលនៅក្នុងឆ្នាំ១៩៧៦” និង “ប្រហែល២ឬ៣ថ្ងៃក្រោយមក បងប្រុសរបស់ខ្ញុំម្នាក់ទៀត ឈ្មោះ ស៊ាង ឈឿន ត្រូវបានឈ្លបដដែលហៅឲ្យចេញពីភូមិផងដែរ។ គាត់ក៏ត្រូវបានបញ្ជូនទៅភ្នំប្រុស ភ្នំស្រីដែរ”។ អ្នកដាក់ពាក្យ ពុំបានផ្តល់សេចក្តីលម្អិតគ្រប់គ្រាន់ក្នុងការកំណត់កាលបរិច្ឆេទនៃការសម្លាប់ទាំងនេះដែរ។ ដូចនេះ មិនមែនមិនសមហេតុផលនោះទេដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិសន្និដ្ឋានថា “អ្នកដាក់ពាក្យសុំមិនបានបង្ហាញថា វាជាការពិត ដែលគាត់បានទទួលរងព្យសនកម្មដោយសារឧក្រិដ្ឋកម្មមួយក្នុងចំណោមឧក្រិដកម្មនានាដែលបានចោទប្រកាន់”។ | សហចៅក្រមស៊ើបអង្កេតអន្តរជាតិត្រូវបាន**បញ្ជាក់**។ |
| 11-VSS-00319 | ស្វ ខេវិនឡេង ហៅ ស្វ ខុងឡេង | អ្នកដាក់ពាក្យសុំបានរៀបរាប់អំពីហេតុការណ៍ដែលបានកើតឡើងក្រៅភូមិភាគកណ្តាល ក្នុងនោះ រួមមានការធ្វើពលកម្មដោយបង្ខំនិងការប្រព្រឹត្តអមនុស្សធម៌។ ជាងនេះទៀតអ្នកដាក់ពាក្យ ថ្លែងថាបងប្រុសរបស់គាត់ត្រូវបានសម្លាប់ ប៉ុន្តែពុំបានបញ្ជាក់អំពីកាលៈទេសៈ ឬក្របខ័ណ្ឌ | ពាក្យសុំមិនអាច**ទទួលយកបាន**។ សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិត្រូវបាន**បញ្ជាក់**។ |

| | | | |
|---|---|---|---|
| | | ពេលវេលាឡើយ។ ហេតុដូចនេះ សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិក្នុងការបដិសេធពាក្យសុំនេះដោយឈរលើមូលដ្ឋានថា "អង្គហេតុដែលបានរៀបរាប់ស្ថិតនៅក្រៅសំណុំរឿង" គឺពុំមែនមិនសមហេតុផលនោះឡើយ។ | |
| 13-VSS-00567 | សូ សារី | ដូចដែលបានបង្ហាញដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដំណើររឿងរបស់អ្នកដាក់ពាក្យគឺមានអសង្គតិភាព។ ដំបូង អ្នកដាក់ពាក្យរៀបរាប់អំពីការសម្លាប់ប្តីរបស់គាត់នៅក្នុងឆ្នាំ១៩៧៥ ដោយថ្លែងថាគេអារកនៅចំពោះមុខគាត់។ ក្រោយមក អ្នកដាក់ពាក្យរៀបរាប់ថាប្តីរបស់គាត់ត្រូវបានគេសម្លាប់នៅក្នុង ឆ្នាំ១៩៧៨ ជាមួយឪពុករបស់គាត់ ហើយចុងក្រោយគាត់បង្ហាញ ថាប្តីរបស់គាត់ត្រូវបានសម្លាប់នៅក្នុងឆ្នាំ១៩៧៥ និង ត្រូវបាន បាញ់នៅចំពោះមុខគាត់។ ដោយពិចារណាលើអសង្គតិភាពទាំងនេះ វាពុំមែនមិនសមហេតុផលនោះទេដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិកំណត់ថា "យោងទៅលើអសង្គតិភាពទាំងនេះ វាមិនអាចទៅរួចទេក្នុងការសន្និដ្ឋានថា វាមានភាពពិតប្រាកដដែលថាគាត់បានទទួលរងការឈឺចាប់ ដោយសារឧក្រិដ្ឋកម្មមួយក្នុងចំណោមក្រិដ្ឋកម្មទាំងឡាយដែលបានចោទប្រកាន់"។ | ពាក្យសុំមិនអាច**ទទួលយកបាន**។ សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិត្រូវបាន**បញ្ជាក់**។ |

| | | | |
|---|---|---|---|
| 11-VSS-00032 | ស៊ឹម រឿន | អ្នកដាក់ពាក្យបានរៀបរាប់ការសម្លាប់ប្តីរបស់គាត់នៅភ្នំប្រុសភ្នំស្រី ក្នុងខេត្តកំពង់ចាម និង ការបង្ខំឲ្យគាត់រៀបអាពាហ៍ពិពាហ៍ ដោយបង្ខំនៅក្នុងស្រុកកំពង់សៀម។ នៅក្នុងពាក្យសុំដំបូង គាត់មិនផ្តល់សេចក្តីលម្អិតគ្រប់គ្រាន់ក្នុងការកំណត់ថាតើហេតុការណ៍ទាំងនេះស្ថិតក្នុងវិសាលភាពនៃសំណុំរឿងឬទេ គ្រាន់តែបង្ហាញថាការសម្លាប់ និងអាពាហ៍ពិពាហ៍ដោយបង្ខំបានកើតឡើងនៅក្នុងឆ្នាំ១៩៧៦។<br><br>ប៉ុន្តែ នៅក្នុងព័ត៌មានបន្ថែម អ្នកដាក់ពាក្យបង្ហាញថាអាពាហ៍ពិពាហ៍ដោយបង្ខំបានកើតឡើងនៅចុងឆ្នាំ១៩៧៦។ ឧក្រិដ្ឋកម្ម ដែលបានចោទថាបានកើតឡើងនេះស្ថិតនៅក្នុងវិសាលភាពពេលវេលានិងដែនដីនៃសំណុំរឿង។ ដូច្នេះ វាពុំមែនគ្មានហេតុផលទេ ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិសន្និដ្ឋានថាហេតុការណ៍ដែលចោទថាបានកើតឡើងគឺស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង។ | សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសឆ្គង។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (D5/219) គួរត្រូវបាន**ទទួលយក**។ |
| 11-VSS-00028 | ស៊ុំ ផុល | អ្នកដាក់ពាក្យបានរៀបរាប់ការធ្វើពលកម្មដោយបង្ខំនៅក្នុងស្រុកកំពង់សៀមក្នុងឆ្នាំ១៩៧៥ និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការសម្លាប់បងប្អូនបង្កើត | ពាក្យសុំ**មិនអាចទទួលយកបាន**។ សេចក្តីសម្រេចរបស់ |

| | | | |
|---|---|---|---|
| | | របស់គាត់ក្នុងឆ្នាំ១៩៧៦។ ហេតុការណ៍នេះស្ថិតក្រៅវិសាលភាពពេលវេលានៃសំណុំរឿង ឬ ពុំមានលក្ខណៈលម្អិតគ្រប់គ្រាន់ក្នុងការកំណត់អំពីក្របខ័ណ្ឌពេលវេលា។ | សហចៅក្រម ស៊ើបអង្កេតអន្តរជាតិត្រូវបាន**បញ្ជាក់**។ |
| 12-VSS-00577 | តែម វត | អ្នកដាក់ពាក្យសុំបានរៀបរាប់អំពីការសម្លាប់បងប្អូនប្រុសបង្កើត របស់គាត់នៅភ្នំប្រុសភ្នំស្រីក្នុងខេត្តកំពង់ចាមនៅក្នុងពេលវេលា មិនជាក់លាក់ និងការសម្លាប់បងប្អូនប្រុសបង្កើតទីពីរដោយ មិនដឹងកាលបរិច្ឆេទ និងទីតាំង ។ ពុំមែនមិនមានហេតុផលនោះ ទេដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិសន្និដ្ឋានថា កាលបរិច្ឆេទនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់គឺមិនច្បាស់លាស់គ្រប់គ្រាន់ក្នុងការកំណត់ថាតើហេតុការណ៍ទាំងនោះបានកើតឡើងនៅក្នុងវិសាលភាពពេលវេលានិង/ឬដែនដីនៃសំណុំរឿង។ | ពាក្យសុំ**មិនអាចទទួលយកបាន**។ សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិត្រូវបាន**បញ្ជាក់**។ |
| 14-VSS-00090 | ថង នាង | អ្នកដាក់ពាក្យបានរៀបរាប់ពីអំពើទាសភាពនិងអំពើអមនុស្សធម៌ដទៃទៀតនៅក្នុងស្រុកកងមាស ខេត្តកំពង់ចាមក្នុងឆ្នាំ១៩៧៥ និង ការសម្លាប់សមាជិកគ្រួសារនៅវត្តអូរត្រកួន ប៉ុន្តែពុំផ្តល់ក្រប ខ័ណ្ឌពេលវេលាលម្អិតឡើយ។ ដូច្នេះ ពុំមែនគ្មានហេតុផលទេ ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិសន្និដ្ឋានថាក្របខ័ណ្ឌពេលវេលាមិន | ពាក្យសុំ**មិនអាចទទួលយកបាន**។ សេចក្តីសម្រេចរបស់សហចៅក្រម ស៊ើបអង្កេតអន្តរជាតិត្រូវបាន**បញ្ជាក់**។ |

| | | | |
|---|---|---|---|
| | | មានលក្ខណៈគ្រប់គ្រាន់ក្នុងការកំណត់ថាវាមានភាពពិតប្រាកដដែលអ្នកដាក់ពាក្យបានទទួលរងព្យសនកម្ម ដោយសារ ឧក្រិដ្ឋកម្មដែលបានចោទប្រកាន់។ | |